# 15 날씨가 맑아서 기분이 좋아요

## ខ្ញុំមានអារម្មណ៍ល្អ ពីព្រោះ(អាកាសធាតុ)មេឃស្រលះល្អ

**학습 안내**
ការណែនាំអំពីមេរៀន

| | |
|---|---|
| □ វត្ថុបំណងមេរៀន | ការនិយាយអំពីអាកាសធាតុនិងអារម្មណ៍ |
| □ វេយ្យាករណ៍ | -네요, -아서/어서 |
| □ ពាក្យថ្មី | អាកាសធាតុនិងរដូវកាល, អារម្មណ៍និងពាក្យបង្ហាញពីអារម្មណ៍ |
| □ ព័ត៌មាន · វប្បធម៌ | អាកាសធាតុប្រទេសកូរ៉េ |

## 대화 1 ការសន្ទនា ១

Track 49



ខាងក្រោមនេះគឺជាកិច្ចសន្ទនារបស់ធូអាន់និងរីហាន់។ អ្នកទាំងពីរកំពុងសួរគ្នាទៅវិញទៅមកថាមានឆ័ត្រ ឬក៏មិនមាន? ដំបូង សូមស្តាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

**투안** 비가 계속 오네요.
ភ្លៀងនៅតែបន្តធ្លាក់រហូត។

**리한** 네, 안 그치네요.
បាទ, ភ្លៀងអត់រាំងសោះ។
투안 씨, 우산 있어요?
ធូអាន់, តើអ្នកមានឆ័ត្រទេ?

**투안** 아니요, 없어요. 리한 씨는요?
អត់ទេ, ខ្ញុំមិនមានឆ័ត្រទេ។ ចុះរីហាន់វិញ?

**리한** 저는 있어요. ខ្ញុំមានឆ័ត្រ។
이따가 저하고 같이 집에 가요.
បន្តិចទៀត ទៅផ្ទះជាមួយខ្ញុំ។

**계속** បន្ត
- 저는 한국어를 계속 공부하고 싶어요.
  ខ្ញុំចង់រៀនភាសាកូរ៉េបន្តទៀត។
- 계속 비가 오면 축구를 할 수 없을 거예요.
  ប្រសិនបើភ្លៀងនៅតែបន្តធ្លាក់ទៀត ប្រហែលជានឹងមិនអាចលេងបាល់ទាត់បានទេ។

**이따가** បន្តិចទៀត
- 지금은 바쁘니까 이따가 오세요.
  ពីព្រោះតែឥឡូវនេះខ្ញុំរវល់សូមមកក្នុងពេលបន្តិចទៀត។
- 우리 이따가 이야기 좀 할까요?
  បន្តិចទៀត ពួកយើងនិយាយគ្នាបន្តិចល្អដែរឬទេ?



តើអ្នកបានស្តាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមសាកល្បងឆ្លើយសំណួរខាងក្រោម។

1. 날씨가 어때요? តើអាកាសធាតុយ៉ាងម៉េចដែរ?
2. 투안 씨는 우산이 있어요? តើធូអាន់មានឆ័ត្រដែរឬទេ?

정답 1. 비가 와요. 2. 아니요, 없어요.

## 어휘 1 ពាក្យថ្មី ១ | 날씨와 계절 អាកាសធាតុនិងរដូវកាល



ប្រទេសកូរ៉េមាន៤រដូវ។ រដូវនីមួយៗមានអាកាសធាតុផ្សេងៗគ្នា។ អញ្ចឹង តោះ! យើងស្វែងយល់អំពីពាក្យដែលទាក់ទងទៅនឹងរដូវ រួមទាំងអាកាសធាតុទាំងអស់គ្នា។



봄
រដូវផ្ការីក



따뜻하다
កក់ក្ដៅ, ក្ដៅល្មម



여름
រដូវក្ដៅ



덥다
ក្ដៅ



가을
រដូវស្លឹកឈើជ្រុះ



시원하다
ត្រជាក់ស្រួល



겨울
រដូវរងា



춥다
ត្រជាក់/រងា

- **봄**은 **따뜻해요**. រដូវផ្ការីក មានអាកាសធាតុក្ដៅល្មម។
- **가을**은 **시원해요**. រដូវស្លឹកឈើជ្រុះ មានអាកាសធាតុត្រជាក់ស្រួល។
- **여름**은 **더워요**. រដូវក្ដៅ មានអាកាសធាតុក្ដៅ។
- **겨울**은 **추워요**. រដូវរងា មានអាកាសធាតុត្រជាក់។

맑다 ស្រលះ
날씨가 좋다 អាកាសធាតុល្អ
날씨가 나쁘다 អាកាសធាតុមិនល្អ
흐리다 មេឃមានពពកខ្មៅដេរដាស
비가 오다 ភ្លៀងធ្លាក់
눈이 오다 ព្រិលធ្លាក់
바람이 불다 ខ្យល់បក់
그치다 រាំង (ភ្លៀង)



សូមកុំមើលពាក្យនៅខាងលើ ហើយសាកល្បងដោះស្រាយសំណួរ។

1. 그림을 보고 알맞은 단어를 연결하세요. សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងពាក្យដែលត្រឹមត្រូវ។

① 

② 

③ 

④ 

㉠ 따뜻하다
㉡ 덥다
㉢ 시원하다
㉣ 춥다

정답 ① ㉡ ② ㉠ ③ ㉣ ④ ㉢

## 문법 1 វេយ្យាករណ៍ ១ | -네요

G15-1

'-네요' ត្រូវបានប្រើនៅពេលដែលយើងមានការភ្ញាក់ផ្អើលដោយបានដឹងពីការពិតអំពីអ្វីមួយ ឬក៏នៅពេលឥឡូវមានអារម្មណ៍ដឹងឬក៏ឃើញអ្វីមួយផ្ទាល់នឹងភ្នែក។ ហើយវាត្រូវបានប្រើជាមួយកិរិយាស័ព្ទឬក៏គុណនាម ដោយមិនគិតថាមានជើងប្រកបឬមិនមានជើងប្រកបឡើយ គឺប្រើប្រាស់ទម្រង់ '-네요' ទាំងអស់។

- 가: 지금 추워요? តើឥឡូវអាកាសធាតុត្រជាក់ដែរឬទេ?
  나: 네, 좀 **춥네요**. បាទ/ ចាំ , វាងត្រជាក់បន្តិច។
- 가: 수피카 씨는 한국 음식을 참 잘 **만드네요**. ស៊ូភីខា ពិតជាពូកែធ្វើម្ហូបកូរ៉េមែន។
  나: 그래요? 감사합니다. ពិតមែនឬ? អរគុណ។

### 비교해 보세요 សូមសាកល្បងធ្វើការប្រៀបធៀប

**✔ រវាង '-네요' និង '-는군요'**

យើងប្រើប្រាស់ '-네요' និង '-는군요' នៅពេលភ្ញាក់ផ្អើលអំពីការពិតអ្វីមួយដែលយើងទើបតែដឹង។ ជាទូទៅគេប្រើ '-네요' នៅពេលដែលអ្នកនិយាយដឹងពីការពិតអ្វីមួយដោយបទពិសោធន៍របស់ខ្លួនឯងផ្ទាល់។ ចំណែកឯ '-는군요' វិញអាចប្រើប្រាស់បានមិនត្រឹមតែនៅពេលដឹងពីការពិតអ្វីមួយដោយបទពិសោធន៍ផ្ទាល់ខ្លួនប៉ុណ្ណោះទេ ថែមទាំងអាចប្រើបាននៅពេលដឹងពីការពិតអ្វីមួយដោយសារការស្ដាប់ដឹងលឺផងដែរ។

- 가: 여기 오는 데 3시간이 걸렸어요.
  나: 아, 여기 오는 데 3시간이나 **걸렸군요**. (O) / 걸렸네요. (X)



តើអ្នកបានយល់អំពីការប្រើប្រាស់ '-네요' ហើយមែនដែរឬទេ? សូមមើលរូបភាពបន្ទាប់មកចូរបញ្ចប់ប្រយោគដូច<ឧទាហរណ៍>។

2. 그림을 보고 〈보기〉처럼 '-네요'를 사용해서 문장을 완성하세요.
សូមមើលរូបភាព បន្ទាប់មកចូរប្រើប្រាស់ '-네요' មកបញ្ចប់ប្រយោគដូច<ឧទាហរណ៍>។

보기



오늘은 날씨가 정말 따뜻하네요. ថ្ងៃនេះអាកាសធាតុ ពិតជាកក់ក្ដៅមែន។

1)  오늘은 날씨가 너무 ____________.

2)  오늘은 날씨가 너무 ____________.

3)  오늘은 날씨가 정말 ____________.

4)  오늘은 비가 정말 많이 ____________.

정답 1) 덥네요 2) 춥네요 3) 시원하네요 4) 오네요

## 대화 2 ការសន្ទនា ២

Track 50

ធូអាន់និងស៊ូរ៉ូកំពុងនិយាយពីរដូវកាលដែលពួកគេចូលចិត្ត។ តើអ្នកទាំងពីរចូលចិត្តរដូវមួយណាជាងគេ? ដំបូង សូមស្តាប់ការសន្ទនាឲ្យបាន២ដងជាមុនសិនរួចហើយចូរថាតាម។

투안 오늘은 날씨가 참 좋네요.
ថ្ងៃនេះអាកាសធាតុ ពិតជាល្អមែន។

수루 네, 요즘은 날씨가 따뜻해서 기분이 정말 좋아요.
ចា, សព្វថ្ងៃនេះពីព្រោះតែអាកាសធាតុក្តៅល្មម ដូច្នេះហើយធ្វើអោយខ្ញុំមានអារម្មណ៍ល្អ។

투안 수루 씨는 봄을 좋아해요?
ស៊ូរ៉ូ, តើអ្នកចូលចិត្តរដូវផ្ការីកឬ?

수루 네, 저는 봄을 가장 좋아해요.
ចា, ខ្ញុំចូលចិត្តរដូវផ្ការីកជាងគេ។
투안 씨는 무슨 계절을 가장 좋아해요?
ធូអាន់, តើអ្នកចូលចិត្តរដូវមួយណាជាងគេ?

투안 저는 겨울을 가장 좋아해요.
ខ្ញុំចូលចិត្តរដូវរងាជាងគេ។

**참 ណាស់**
- 오늘 참 덥네요.
  ថ្ងៃនេះ ក្តៅណាស់។
- 영화가 참 재미있어요.
  ភាពយន្តល្អមើលណាស់។

**무슨 អ្វី**
- 한국에서 무슨 일을 하고 싶어요?
  តើអ្នកចង់ធ្វើការអ្វី នៅប្រទេសកូរ៉េ?
- 무슨 과일을 좋아해요?
  តើអ្នកចូលចិត្តផ្លែឈើអ្វី?

តើអ្នកបានស្តាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមសាកល្បងឆ្លើយសំណួរខាងក្រោម។

1. 오늘은 날씨가 어때요? តើថ្ងៃនេះអាកាសធាតុយ៉ាងម៉េចដែរ?
2. 투안 씨는 무슨 계절을 좋아해요? តើធូអាន់ចូលចិត្តរដូវអ្វី?
3. 수루 씨는 왜 기분이 좋아요? ហេតុអ្វីបានជាស៊ូរ៉ូមានអារម្មណ៍ល្អ?

정답 1. 참 좋아요. 2. 겨울을 좋아해요. 3. 요즘 날씨가 따뜻해서 기분이 좋아요.

## 어휘 2 ពាក្យថ្មី ២ | 기분과 감정 អារម្មណ៍និងពាក្យបង្ហាញពីអារម្មណ៍



តើពាក្យដែលទាក់ទងទៅនឹងអារម្មណ៍ រួមទាំងពាក្យបង្ហាញពីអារម្មណ៍នឹងមានអ្វីខ្លះ?
តោះ! រៀនស្វែងយល់ទាំងអស់គ្នា។



기분이 좋다
អារម្មណ៍ល្អ



기쁘다
សប្បាយចិត្ត



즐겁다
រីករាយ



신나다
រំភើបរីករាយ



기분이 나쁘다
អារម្មណ៍មិនល្អ



슬프다
កំសត់, ក្រៀមក្រំ



피곤하다
អស់កម្លាំង



졸리다
ងងុយគេង



외롭다
ឯកោ, កណ្ដោចកណ្ដែង



우울하다
បាក់ទឹកចិត្ត



상쾌하다
អារម្មណ៍ស្រស់ស្រាយ



행복하다
មានសុភមង្គល

- 시험을 잘 쳐서 **기분이 좋아요**. ខ្ញុំមានអារម្មណ៍ល្អ ពីព្រោះខ្ញុំប្រលង(ធ្វើ)បានល្អ។
- 친구한테서 편지를 받아서 정말 **기뻐요**. ខ្ញុំមានអារម្មណ៍សប្បាយចិត្ត ពីព្រោះខ្ញុំបានទទួលសំបុត្រពីមិត្តភក្តិរបស់ខ្ញុំ។
- 시험을 못 쳐서 **기분이 나빠요**. ខ្ញុំមានអារម្មណ៍មិនល្អទេ ពីព្រោះខ្ញុំប្រលង(ធ្វើ)មិនបានល្អ។
- 영화가 너무 **슬퍼서** 울었어요. ខ្ញុំបានយំ ពីព្រោះភាពយន្តកំសត់ពេក។
- 일을 많이 해서 **피곤해요**. ខ្ញុំអស់កម្លាំង ពីព្រោះខ្ញុំបានធ្វើការច្រើន។
- 어제 잠을 못 자서 **졸려요**. ខ្ញុំងងុយគេង ពីព្រោះកាលពីម្សិលមិញខ្ញុំមិនបានគេង។



សូមរំលឹកពីពាក្យដែលបានរៀននៅខាងលើម្ដងទៀត បន្ទាប់មកចូរសាកល្បងដោះស្រាយសំណួរខាងក្រោម។

1. 그림을 보고 알맞은 단어를 연결하세요.
សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងពាក្យដែលត្រឹមត្រូវ។

① 
② 
③ 
④ 

㉠ 슬프다　㉡ 외롭다　㉢ 피곤하다　㉣ 기분이 좋다

정답 ① ㉢ ② ㉣ ③ ㉠ ④ ㉡

## 문법 2 វេយ្យាករណ៍ ២ | -아서/어서

G15-2

យើងប្រើទម្រង់នេះជាមួយកិរិយាស័ព្ទឬគុណនាម។ អត្ថន័យនៅខាងមុខវា គឺជាហេតុផល/មូលហេតុរបស់លទ្ធផលនៃអត្ថន័យខាងក្រោយវា។

| ㅏ, ㅗ → **-아서** | ㅓ, ㅜ, ㅣ-ល- → **-어서** | 하다 → **해서** |
|---|---|---|
| 가다 → **가서**<br>좋다 → 좋**아서** | 먹다 → 먹**어서**<br>있다 → 있**어서** | 공부하다 → 공부**해서**<br>친절하다 → 친절**해서** |

- 배가 **아파서** 병원에 갔어요. ខ្ញុំបានទៅមន្ទីរពេទ្យ ពីព្រោះខ្ញុំឈឺពោះ។
- 약속이 **있어서** 먼저 집에 갔어요. ខ្ញុំបានទៅផ្ទះមុន ពីព្រោះខ្ញុំមានណាត់។

### 크메르어와 한국어의 공통점과 차이점 ចំណុចដូចគ្នានិងខុសគ្នារវាងភាសាខ្មែរនិងភាសាកូរ៉េ

នៅក្នុងភាសាខ្មែរ នៅពេលដែលភ្ជាប់ប្រយោគនិយាយពីមូលហេតុ ហេតុផល ឬលទ្ធផល យើងប្រើពាក្យដូចជា៖ "ពីព្រោះ, ដោយសារ, ពីព្រោះ....ដូចនេះហើយ, ដោយសារ....ដូចនេះហើយ" ដើម្បីភ្ជាប់ប្រយោគទាំងពីរ, ហើយជាធម្មតាប្រយោគបញ្ជាក់ពីមូលហេតុឬហេតុផល គឺស្ថិតនៅខាងក្រោយពាក្យដែលបញ្ជាក់ពីមូលហេតុ។ រីឯនៅក្នុងភាសាកូរ៉េវិញ គេប្រើពាក្យបន្ថែមចុង '-아서/어서' មកភ្ជាប់ហើយមូលហេតុឬហេតុផល គឺស្ថិតនៅខាងមុខប្រយោគ។



តើអ្នកបានយល់ពីការប្រើប្រាស់វេយ្យាករណ៍ '-아서/어서' ហើយមែនដែរឬទេ? ចូរសាកល្បងបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

2. 그림을 보고 〈보기〉처럼 '-아서/어서'를 사용해서 대화를 완성하세요

សូមមើលរូបភាព ហើយចូរប្រើប្រាស់ '-아서/어서' មកបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

보기



가: 무슨 계절을 좋아해요? តើអ្នកចូលចិត្តរដូវអ្វី?

나: 날씨가 따뜻해서 봄을 좋아해요.

ខ្ញុំចូលចិត្តរដូវផ្ការីក ពីព្រោះវាមានអាកាសធាតុក្តៅល្មម។

1) 

가: 무슨 계절을 좋아해요?

나: 날씨가 ________________ 가을을 좋아해요.

2) 

가: 무슨 계절을 좋아해요?

나: 눈이 ________________ 겨울을 좋아해요.

3) 

가: 오늘 기분이 어때요?

나: 날씨가 ________________ 기분이 좋아요.

4) 

가: 오늘 기분이 어때요?

나: 비가 ________________ 기분이 안 좋아요.

정답 1) 시원해서 2) 와서 3) 좋아서 4) 와서

## 활동 សកម្មភាព

〈보기〉처럼 여러분 나라의 계절과 날씨를 소개해 보세요.
ចូរសាកល្បងណែនាំអំពី រដូវកាលនិងអាកាសធាតុប្រទេសរបស់អ្នកទាំងអស់គ្នាដូច<ឧទាហរណ៍>។

보기

### 한국의 계절

한국에는 봄, 여름, 가을, 겨울이 있습니다. 봄은 날씨가 따뜻합니다. 여름은 날씨가 덥습니다. 그리고 비가 많이 옵니다. 가을은 날씨가 시원합니다. 겨울은 날씨가 춥습니다. 그리고 눈이 옵니다.

### រដូវរបស់ប្រទេសកូរ៉េ

នៅប្រទេសកូរ៉េមាន រដូវផ្ការីក រដូវក្តៅ រដូវស្លឹកឈើជ្រុះ និងរដូវរងា។ នៅរដូវផ្ការីក មានអាកាសធាតុក្តៅល្មម។ នៅរដូវក្តៅ មានអាកាសធាតុក្តៅ ហើយមានភ្លៀងធ្លាក់ច្រើន។ នៅរដូវស្លឹកឈើជ្រុះមានអាកាសធាតុត្រជាក់ស្រួល។ នៅរដូវរងា មានអាកាសធាតុត្រជាក់ និងមានព្រិលធ្លាក់។



នៅប្រទេសកម្ពុជាគឺខុសពីប្រទេសកូរ៉េដែលមានត្រឹមតែរដូវប្រាំងនិងរដូវវស្សាតែប៉ុណ្ណោះ តើមែនដែរឬទេ? នៅប្រទេសកូរ៉េមាន៤រដូវ ហើយតាមរដូវនីមួយៗមានអាកាសធាតុខុសៗគ្នា។ សូមអាន<ឧទាហរណ៍> ខាងលើ ហើយចូរសាកល្បងឆ្លើយនឹងសំណួរខាងក្រោម។

✚ 알맞은 말에 ✔하세요. សូមគូសសញ្ញា ✔ ទៅលើចម្លើយដែលត្រឹមត្រូវ។

(1) 봄은 날씨가 / រដូវផ្ការីក មានអាកាសធាតុ
□ 따뜻합니다. / ក្តៅល្មម។
□ 시원합니다. / ត្រជាក់ស្រួល។

(2) 겨울은 춥습니다. 그리고 / រដូវរងា មានអាកាសធាតុត្រជាក់។ និងមាន
□ 비가 옵니다. / ភ្លៀងធ្លាក់។
□ 눈이 옵니다. / ព្រិលធ្លាក់។

(3) 날씨가 아주 덥습니다. 지금은 / មានអាកាសធាតុក្តៅខ្លាំងណាស់។ ឥឡូវគឺជា
□ 여름입니다. / រដូវក្តៅ។
□ 가을입니다. / រដូវស្លឹកឈើជ្រុះ។

정답 (1) 따뜻합니다. (2) 눈이 옵니다. (3) 여름입니다.

## 퀴즈 លំហាត់តេស្តសាកល្បង

✚ 다음 그림을 보고 생각나는 계절은 뭐예요? ចូរមើលរូបភាពខាងក្រោម ហើយតើអ្នកគិតថាវាជារដូវអ្វី?





?

정답 여름

## 정보 ព័ត៌មាន

### 한국의 사계절 រដូវទាំង៤របស់ប្រទេសកូរ៉េ




| | | | | | | | |
|---|---|---|---|---|---|---|---|
| 겨울 | រដូវរងា | 봄 | រដូវផ្ការីក | 여름 | រដូវក្ដៅ | 가을 | រដូវស្លឹកឈើជ្រុះ |
| 12월 | ខែធ្នូ | 3월 | ខែមីនា | 6월 | ខែមិថុនា | 9월 | ខែកញ្ញា |
| 1월 | ខែមករា | 4월 | ខែមេសា | 7월 | ខែកក្កដា | 10월 | ខែតុលា |
| 2월 | ខែកុម្ភៈ | 5월 | ខែឧសភា | 8월 | ខែសីហា | 11월 | ខែវិច្ឆិកា |

## 내용 확인 ពិនិត្យខ្លឹមសារ

✚ 빈칸에 알맞은 말을 쓰세요. សូមបំពេញចន្លោះនូវពាក្យដែលត្រឹមត្រូវ។

(1) 12월부터 2월까지는 ‘ ’입니다. ចាប់ពីខែធ្នូ ដល់ខែកុម្ភៈ គឺជារដូវរងា។

(2) 겨울에는 ‘ ’이/가 옵니다. នៅរដូវរងា មានព្រិលធ្លាក់។

(3) 여름은 날씨가 ‘ ’. រដូវក្ដៅ មានអាកាសធាតុក្ដៅ។

정답 (1) 겨울 (2) 눈 (3) 덥습니다

# EPS-TOPIK 듣기 វិញ្ញាសាស្តាប់ EPS-TOPIK



សំណួរទី១គឺជាពាក្យនិយាយពីរដូវ, សំណួរទី២គឺជាពាក្យនិយាយពីអាកាសធាតុ។
សូមស្តាប់ដោយយកចិត្តទុកដាក់ ហើយជ្រើសរើសពាក្យដែលអ្នកបានស្តាប់លឺ។

[1~2] 들은 것을 고르십시오. ចូរជ្រើសរើសចម្លើយដែលអ្នកបានស្តាប់លឺ។

Track 51

1. ① 봄　② 여름　③ 가을　④ 겨울

2. ① 더워요　② 추워요　③ 맑아요　④ 흐려요



បន្ទាប់ទៅនេះ គឺជាសំណួរដែលតម្រូវឲ្យស្តាប់ការសន្ទនា ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។
មុននឹងស្តាប់ការសន្ទនា សូមពិនិត្យមើលខ្លឹមសាររបស់សំណួរជាមុនសិន។

[3~5] 이야기를 듣고 질문에 알맞은 대답을 고르십시오.
សូមស្តាប់ការនិយាយ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។

3. 지금은 무슨 계절입니까? តើឥឡូវនេះជារដូវអ្វី?
① 봄　② 여름
③ 가을　④ 겨울

4. 오늘 날씨는 어떻습니까? តើអាកាសធាតុថ្ងៃនេះយ៉ាងម៉េចដែរ?
① 비가 옵니다.　② 눈이 옵니다.
③ 날씨가 좋습니다.　④ 날씨가 흐립니다.

5. 남자는 무슨 계절을 좋아합니까? តើបុរសចូលចិត្តរដូវអ្វី?
① 봄　② 여름
③ 가을　④ 겨울



### 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្តាប់

1. 남: 가을 រដូវស្លឹកឈើជ្រុះ
2. 여: 추워요. ត្រជាក់
3. 남: 오늘 날씨가 많이 춥네요. ថ្ងៃនេះអាកាសធាតុត្រជាក់ខ្លាំង។
   여: 하지만 눈이 와서 기분이 너무 좋아요. ប៉ុន្តែខ្ញុំមានអារម្មណ៍ល្អណាស់ ពីព្រោះមានព្រិលធ្លាក់។
4. 남: 지금 비가 와요? តើឥឡូវមានភ្លៀងធ្លាក់ឬទេ?
   여: 아니요. 안 와요. 날씨가 아주 맑아요. អត់ទេ, មិនមានភ្លៀងធ្លាក់ទេ។ អាកាសធាតុបើកថ្ងៃស្រលះល្អណាស់។
5. 남: 수미 씨는 무슨 계절을 좋아해요? ស៊ូមី, តើអ្នកចូលចិត្តរដូវអ្វី?
   여: 저는 여름을 좋아해요. 투안 씨는요? ខ្ញុំចូលចិត្ត រដូវក្តៅ។ ចុះធូអាន់វិញ?
   남: 전 봄을 좋아해요. ខ្ញុំចូលចិត្តរដូវផ្ការីក។

정답 1. ③ 2. ② 3. ④ 4. ③ 5. ①

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-15

1. 들은 것을 고르십시오. ចូរជ្រើសរើសចម្លើយដែលអ្នកបានស្តាប់លឺ។

   ① 더워요. ② 맑아요. ③ 추워요. ④ 흐려요.

2. 대화를 듣고 질문에 알맞은 것을 고르십시오.
   សូមស្តាប់ការសន្ទនា បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។

   부산은 날씨가 어때요? តើប៊ូសានមានអាកាសធាតុយ៉ាងម៉េចដែរ?

   ① 눈이 와요. ② 비가 와요.
   ③ 날씨가 좋아요. ④ 날씨가 나빠요.

### 확장 연습 듣기 대본 អត្ថបទស្តាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: 맑아요. មេឃស្រលះល្អ។
2. 남: 부산은 지금 날씨가 좋아요? តើឥឡូវនៅប៊ូសានមានអាកាសធាតុល្អដែរឬទេ?
   여: 아니요, 안 좋아요. 바람이 불고 추워요. អត់ទេ, អាកាសធាតុមិនល្អទេ។ មានខ្យល់បក់ ហើយត្រជាក់។

정답 1. ② 2. ④

# EPS-TOPIK 읽기 វិញ្ញាសារអាន EPS-TOPIK



សំណួរទី១ គឺជាពាក្យនិយាយពីអាកាសធាតុ, សំណួរទី២ គឺជាពាក្យនិយាយពីអារម្មណ៍និងពាក្យទាក់ទងទៅនឹងអារម្មណ៍។ សូមជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងរូបភាព។

[1~2] 다음 그림을 보고 맞는 문장을 고르십시오.
សូមមើលរូបភាពខាងក្រោម ហើយចូរជ្រើសរើសយកល្បះដែលត្រឹមត្រូវ។

1. 

① 더워요. ② 추워요.
③ 흐려요. ④ 시원해요.

2. 

① 슬픕니다. ② 외롭습니다.
③ 행복합니다. ④ 피곤합니다.



ខាងក្រោមនេះគឺសំណួរទាក់ទងទៅនឹងអាកាសធាតុរួមទាំងរដូវកាល។ សូមរំលឹកអំពីអ្វីដែលអ្នកបានរៀនរួចមកហើយនោះបណ្តើរ និងធ្វើការដោះស្រាយសំណួរបណ្តើរ។

[3~5] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

3. 필리핀에는 겨울이 없어요. 그래서 ________________.
នៅប្រទេសហ្វីលីពីន មិនមានរដូវរងាទេ។ ដូចនេះ ព្រិលមិនធ្លាក់ទេ។

① 너무 추워요 ② 눈이 안 와요 ③ 겨울이 있어요 ④ 날씨가 흐려요

4. 가: ______________________? តើថ្ងៃនេះអាកាសធាតុយ៉ាងណាដែរ?
나: 아주 좋아요. 맑아요. អាកាសធាតុល្អណាស់។ មេឃស្រឡះល្អ។

① 가을이 없어요 ② 비가 많이 와요
③ 오늘 날씨가 어때요 ④ 무슨 계절을 좋아해요

5. 여름은 날씨가 _______ 저는 여름을 안 좋아해요.
ខ្ញុំមិនចូលចិត្តរដូវក្តៅទេ ពីព្រោះនៅរដូវក្តៅ អាកាសធាតុក្តៅ។

① 없어서 ② 있어서 ③ 더워서 ④ 추워서

정답 1. ④ 2. ③ 3. ② 4. ③ 5. ③



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~3] 다음 그림을 보고 맞는 문장을 고르십시오. ចូរមើលរូបភាពខាងក្រោម ហើយជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

1. 

① 봄 ② 여름
③ 가을 ④ 겨울

2. 

① 더워요. ② 추워요.
③ 눈이 와요. ④ 비가 와요.

3. 

① 신나요. ② 졸려요.
③ 피곤해요. ④ 기분이 나빠요.

[4~6] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

4.

주말에 ________이/가 좋으면 친구들과 함께 축구를 하려고 합니다. 비가 안 오면 좋겠습니다.

ពេលចុងសប្តាហ៍ ប្រសិនបើអាកាសធាតុល្អ ខ្ញុំមានបំណងចង់លេងបាល់ទាត់ជាមួយមិត្តភក្តិរបស់ខ្ញុំ។ វាពិតជាល្អប្រសិនបើមិនមានភ្លៀងធ្លាក់។

① 계절 ② 날씨 ③ 요일 ④ 휴일

5.

지난주에는 날씨가 따뜻했는데 이번 주부터 날씨가 ________. 두꺼운 옷을 입어야 할 것 같습니다.

កាលពីអាទិត្យមុនអាកាសធាតុក្តៅល្មម  ប៉ុន្តែចាប់ពីអាទិត្យនេះទៅ អាកាសធាតុចាប់ផ្តើមចុះត្រជាក់។ ប្រហែលជាត្រូវស្លៀកពាក់សម្លៀកបំពាក់សាច់ក្រាស់ៗហើយទើបបាន។

① 더워졌습니다 ② 좋아졌습니다
③ 추워졌습니다 ④ 시원해졌습니다

6.

한국에 ________ 눈을 처음 봤습니다. 우리나라는 춥지 않아서 눈이 오지 않기 때문입니다.

ខ្ញុំបានឃើញព្រិលជាលើកដំបូង ពេលបានមកដល់ប្រទេសកូរ៉េ។ ពីព្រោះនៅប្រទេសរបស់ខ្ញុំ អាកាសធាតុមិនត្រជាក់ដូច្នេះហើយមិនមានព្រិលធ្លាក់ទេ។

① 오면 ② 와서 ③ 오게 ④ 와도

정답 1. ④ 2. ③ 3. ② 4. ② 5. ③ 6. ②